ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៣

នៅក្នុងឆមាសទី១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មលើការដ្ឋានជាច្រើន ដោយផ្សារភ្ជាប់បទដ្ឋានការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងការកំណត់គោលការណ៍ប្រតិបត្តិហិរញ្ញវត្ថុរបស់ព្រឹទ្ធសភា សម្រាប់ឆ្នាំ២០១៣ ការរៀបចំថវិកាតាមកម្មវិធីនៅគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមយុទ្ធសាស្ត្រកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកសាងសេចក្តីសម្រេចនានា កសាងគោលនយោបាយសង្គមកិច្ច ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ក្នុងរយៈពេលមួយឆមាសនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គ ប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ចំនួន១០លើក ចូលរួមក្នុងពិធីជំនួបសវនាការរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមសិក្ខាសាលា ប្រជុំជាមួយប្រធានគណៈកម្មការនានា ធ្វើបទឧទ្ទេសនាម រៀបចំសេចក្តីសម្រេចផ្សេងៗ បន្តជម្រុញការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ពង្រឹងការងាររបស់ PIC ជួបពិភាក្សាជាមួយភ្ញៀវជាតិ-អន្តរជាតិ ប្រជុំពិភាក្សាការងារ អញ្ជើញជាកិត្តិយសជាអធិបតីក្នុងពិធីផ្សេងៗ ទស្សនកិច្ចសិក្សាក្រៅប្រទេស និងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន២៧០០ច្បាប់ ។

### ១.សេវាទ្រទ្រង់មុខងារនីតិកម្ម

-បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០៥លើក ប្រជុំវិសាមញ្ញ ចំនួន០១លើក និងប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០៤លើក និងបានពិនិត្យឲ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន១៥ ដែលព្រឹទ្ធសភាទទួលបានពីរដ្ឋសភា ។

### ២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-បានចុះបំពេញការងារជាមួយសមាជិក-សមាជិកាព្រឹទ្ធសភា ក្នុងជំនួបសវនាការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្លឹបអ្នកកាសែតកម្ពុជា និងវិទ្យាស្ថានសភាកម្ពុជា បានចំនួន១០លើក ដើម្បីស្វែងយល់អំពីការងារដែលពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការដែលក្រសួងស្ថាប័ននានារបស់រដ្ឋាភិបាលដែលនឹងកំពុងអនុវត្ត ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក-សមាជិកាព្រឹទ្ធសភា អញ្ជើញចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេស ចំនួន៧៨២លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ព្យាបាលជំងឺ ចែកប័ណ្ណកម្មសិទ្ធិដីធ្លី ពិនិត្យការដ្ឋានសាងសង់សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងកិច្ចប្រជុំផ្សេងៗ និងពិធីផ្លូវការផ្សេងៗសរុប ចំនួន៦៨២លើក ។

-ទទួលពាក្យបណ្តឹង ចំនួន២៩ករណី និងបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបានចំនួន២៤ករណី ។

**៤.សេវាទ្រទ្រង់មុខងារព័ត៌មាន៖**

-រៀបចំបែបបទ និងអមដំណើរសមាជិក-សមាជិកាព្រឹទ្ធសភា ចុះបំពេញបេសកកម្មតាមបណ្តាខេត្តក្រុង ចំនួន០៧លើក ដើម្បីស្វែងរកព័ត៌មាន អំពីការអនុវត្តច្បាប់ គម្រោងអភិវឌ្ឍនានា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិ និងវិស័យផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ ។

**៥.ការងារអន្តរជាតិ៖**

-រៀបចំជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយស្ថានទូតជប៉ុន អគ្គរដ្ឋទូតប៉ូឡូញ នាយកប្រតិបត្តិ PIC នាយកមហាវិទ្យាល័យ Hanzhong University តំណាងSES គណៈប្រតិភូវិនិយោគចិន អគ្គលេខាធិការរដ្ឋសភាឡាវ អគ្គលេខាធិការរងរដ្ឋសភា នៃព្រះរាជាណាចក្រថៃឡង់ដ៍ តំណាងមូលនិធិអាស៊ី តំណាងមូលនិធិខុនរ៉ាដ អាឌិនណៅអ៊ែរ និងសាស្ត្រាចារ្យ Surya Prasad Subedi អ្នកធ្វើរបាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពី ស្ថានភាពសិទ្ធិមនុស្សក្នុងព្រះរាជាណាចក្រកម្ពុជា ។

-បានរៀបចំបែបបទជូនសមាជិក-សមាជិកាគណៈកម្មការនានារបស់ព្រឹទ្ធសភា ចំនួន១៥រូប

អញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ សន្និបាត វេទិកា និងពិធីផ្សេងៗ នៅប្រទេសថៃ ចិន ឡាវ វៀតណាម ទួរគី សហព័ន្ធរុស្ស៊ី អូស្ត្រាលី កាណាដា សាធារណរដ្ឋអេក្វាឌ័រ និងម៉ូណាកូ ។

-បានទំនាក់ទំនង និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូរអន្តរជាតិ ជាមួយKoica ស្ថានទូត Singapore, India, Brunei, Philippine, បែលហ្ស៊ិក ឥណ្ឌូនេស៊ី ម៉ាឡេស៊ី រុស្ស៊ី មីយ៉ាន់ ថៃ ឡាវ ដាណឺម៉ាក អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៦.ទំនាក់ទំនងសាធារណៈ**

-បានទំនាក់ទំនងជាមួយ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរអប្សរា អាកាសចរស៊ីវិល និងអភិបាលខេត្ត-ក្រុង ដើម្បីសម្រួលបែបបទជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្នុង និងក្រៅប្រទេស ។ បានទំនាក់ទំនងជាមួយ ស្ថានីយ៍ទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យពុទ្ធិសាស្ត្រ CUS, CMTC, CDC, AEU, ECCC, CWF, NiDA Honh kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន២៨៧៩នាក់ ។

**៧.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

**+ការបណ្តុះបណ្តាលធនធានមនុស្សក្នុងស្ថាប័ន**

-វគ្គបណ្តុះបណ្តាលបានចំនួន២៦វគ្គ មានដូចជា៖ វគ្គថវិកាសាធារណៈ វគ្គភាសាចិនជំហានទី២, ទី៣, វគ្គភាសាវៀតណាមបន្ត វគ្គភាសាជប៉ុន វគ្គហ្វឹកហ្វឺនការងារ វគ្គការអភិវឌ្ឍន៍ធនធានមនុស្ស វគ្គAdobe Photoshop, វគ្គការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់, វគ្គផែនការយុទ្ធសាស្ត្រជំហាន២, វគ្គវិធីសាស្ត្រស្រាវជ្រាវជំហាន២, វគ្គភាសាអង់គ្លេស, វគ្គហ្វឹកហ្វឺនការងារ, វគ្គសម័យប្រជុំព្រឹទ្ធសភា, វគ្គតម្រង់ទិសក្រុមទី១, ក្រុមទី២, ក្រុមទី៣, វគ្គមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង វគ្គកិច្ចការអ្នកនាំពាក្យ, វគ្គមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង , វគ្គតបណ្តាញ, វគ្គការបំពេញតួនាទីតំណាង និងតួនាទីត្រួតពិនិត្យការអនុវត្តច្បាប់របស់សមាជិកព្រឹទ្ធសភា, វគ្គវិភាគច្បាប់, វគ្គភាសាអង់គ្លេសសម្រាប់មន្ត្រីសភាកម្ពុជា, និងវគ្គការប្រើប្រាស់ភាសាខ្មែរក្នុងការសរសេរឲ្យបានត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ ។

**+ការបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស**

-វគ្គបណ្តុះបណ្តាលបាន ចំនួន០៨វគ្គ មានដូចជា៖ វគ្គ Specialized Programme on Internet

Working Design and LAN WAN Administrative at the Center for Development of Advanced Computing, វគ្គCertificate of Proficiency in Graphic & Web Design at the Aptech Ltd, វគ្គ Progress to Proficiency Advanced at the English and Foreign Languages University, Certificate of Proficiency in English Communication, វគ្គស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ, វគ្គស្តីពីការគ្រប់គ្រងលទ្ធផលសម្រាប់មន្ត្រីរាជរដ្ឋាភិបាល, វគ្គស្តីពីការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិច វគ្គមន្ត្រីសភា, និងវគ្គComputer Hardware& Networking, Graphic Designing& English Communication WebDesign & Development ។

+<u>អាហារូបករណ៍ក្នុងប្រទេស</u>

-មន្ត្រីចំនួន១០៥រូប ទទួលបានការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងភាសាអង់គ្លេសទូទៅ នៅសាកលវិទ្យាល័យបញ្ញាជាតិ សាកលវិទ្យាល័យហ្វាម៉ាន់ សាកលវិទ្យាល័យប៊ែលធីអន្តរជាតិ វិទ្យាស្ថានសភាកម្ពុជា វិទ្យាស្ថានប៊ុណ្ណាកម្ពុជា និងមជ្ឈមណ្ឌលហុងកុងសិនធ័រ ។

+<u>អាហារូបករណ៍ក្រៅប្រទេស</u>

-មន្ត្រីចំនួន៦២រូប ទទួលបានអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បណ្ឌិត ភាសាចិន និងខាងICT នៅប្រទេសចិន, ប្រទេសវៀតណាម និងប្រទេសឥណ្ឌា ។

**៨.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-បន្តការសាងសង់អគារ០៣ខ្នង០៣ជាន់ ការបំពាក់ជណ្តើរយន្ត ការជម្រុញគម្រោងជំនួយសុំបន្ថែម និងអនុវត្តបញ្ចប់គម្រោងបច្ចេកវិទ្យាក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Camserv Cambodia(ម៉ាឡេស៊ី) ។ ការជួសជុលនាយកដ្ឋានរដ្ឋបាល សាលពិសេស សាលសិក្ខាសាលាខាងជើង ដំណើរការកំចាត់សត្វកណ្តៀរនៅអាគារក្រហម ។

-រដ្ឋាភិបាលចិនផ្តល់ជំនួយជណ្តើរយន្ត ចំនួន០៣គ្រឿង និងកំពុងសិក្សាកាប៊ីនភ្លើង និងការកសាងអគារមួយខ្នងបន្ថែមទៀត ។

**៩.សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន១០២លើក ។

-រៀបចំឯកសារលទ្ធកម្ម នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ថតចម្លងឯកសា ចំនួន៨៩៤សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៥៥២ក្បាល ដោះស្រាយសម្ភារ និងសំណើថវិកា ចំនួន១៣៤៧សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូន ចំនួន៧៣៨លើក ។

-បានទទួលកុំព្យូទ័រ Laptop ចំនួន១០០គ្រឿង ជាអំណោយរបស់រដ្ឋាភិបាលជប៉ុន និងកៅអីពូកទឹកមាស ចំនួន១៦២គ្រឿង ។ បានប្រគល់ ម៉ាស៊ីនត្រជាក់ កុំព្យូទ័រ តុកុំព្យូទ័រ កៅអីពូកទឹកមាស កៅអីពូកជើងដែក និងស្លាកលេខរថយន្ត ចំនួន២៧៧គ្រឿង និងបិទលេខកូដកុំព្យូទ័រយួរដៃ កុំព្យូទ័រ Desktop, Ipad ទូដែកដាក់ឯកសារ កៅអីវិល និងសំភារៈការិយាល័យផ្សេងៗទៀត ចំនួន៩៩គ្រឿង។ តម្លើង បញ្ចូលហ្គាស ជួសជុល ទូរទស្សន៍ ព្រីនធ័រ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនថតចម្លង ទូទឹកកក ទូរស័ព្ទ កៅអីវិលធំ សោតុ ឌីសង់ទ័រ បន្ទប់ទឹក បណ្តាញអគ្គិសនី ប្តូរអំពូល ព្រី កុងតាក់ និងដាក់នាឡិកា ចំនួន៦៥១គ្រឿង។

-បានជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode,Office ចុះតាមដាន Internet និង Network សរុបចំនួន៣២០គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន២៦៨ប្រធានបទ ។

## II.**ទិសដៅការងារឆមាសទី២**

១-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងពេញអង្គព្រឹទ្ធសភា ។

២-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ អន្តរជាតិ និងអង្គទូតនានា ។

៣-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

៥-ត្រៀមលិខិតថ្វាយព្រះពរ និងជូនពរក្នុងឱកាសបុណ្យចូលឆ្នាំសាកល ឆ្នាំ២០១៤ ។

៦-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភាតាមភូមិភាគ ។

៧-ការត្រៀមរៀបចំពិធីបុណ្យភ្ជុំបិណ្ឌ ទិវាប្រារព្ធព្រះរាជពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមរតនៈកោដ្ឋ ព្រះរាជពិធី គ្រងព្រះបរមរាជ្យសម្បត្តិរបស់ ព្រះមហាក្សត្រ ពិធីបុណ្យឯករាជ្យជាតិ បុណ្យអុំទូក អកអំបុក សំពះព្រះខែ។

៨-ការរៀបចំប្រទីបព្រឹទ្ធសភា។

៩-ការត្រៀមរៀបចំបំពាក់ការបិនភ្លើង ប្រព័ន្ធអគ្គិសនី លូទឹក សួនច្បារ នៅក្នុងបរិវេណការដ្ឋាន ៣ខ្នង និងក្នុងបរិវេណព្រឹទ្ធសភា។

១០-ត្រៀមទទួល និងសម្ពោធអគារ៣ខ្នង ៣ជាន់ ជំនួយរបស់រដ្ឋាភិបាលចិន និងបន្តស្វះស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការ ។

១១-រៀបចំគម្រោងថវិកាឆ្នាំ២០១៤ របស់ព្រឹទ្ធសភា និងធ្វើរបាយការណ៍ចំណាយថវិការបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០១៣ ដាក់ជូនគណៈកម្មការទី២ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១២-ជម្រុញការបើកវគ្គសិក្សា និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងការស្វែងរកអាហារូបករណ៍ក្នុង និងក្រៅប្រទេស។

១៣-ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិគ្រប់អង្គភាពអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំឆ្នាំ២០១៣ និងការរៀបចំផែនការប្រតិបត្តិឆ្នាំ២០១៤ ។

១៤- ការរៀបចំដេញថ្លៃគម្រោងលទ្ធកម្មជំហានទី២។

១៥- បញ្ចប់ការកែលម្អរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

១៦-ត្រៀមចូលរួមបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ អាណត្តិទី៥ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ។

១៧-ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា និងសភាកម្ពុជា បើកទ្វារទៅខាងក្រៅដើម្បីរកជំនួយ និងការគាំទ្របន្ថែម ។

១៨-បន្តរៀបចំ និងដាក់ឲ្យអនុវត្តអង្គភាពថវិកាសម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៣ ។

១៩-បន្តពង្រឹងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យកាន់ស៊ីជម្រៅ ។

២០-ត្រៀមរៀបចំពិធីបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រី ។

២១-ការចុះសួរសុខទុក្ខប្រជាពលរដ្ឋ កម្លាំងប្រដាប់អាវុធ ពិសេសក្រុមដែលបានចងសម្ព័ន្ធជាមួយនឹងព្រឹទ្ធសភា ។

២២-ការគិតគូដល់ការជីវភាពមន្ត្រីរាជការ និងការចំណាយធនធានមធ្យោបាយដល់គ្រប់អង្គភាព

២៣-បន្តសិក្សា និងរៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហមអគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងឆមាសទី១ ឆ្នាំ២០១៣ នេះអគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងមមាញឹកក្នុងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំវិសាមញ្ញ ប្រជុំពេញអង្គលើកទី៣ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់ចំនួន១៥ច្បាប់ ។

តាមយុទ្ធសាស្ត្រកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការដ្ឋានកំណត់គោលការណ៍ប្រតិបត្តិហិរញ្ញវត្ថុរបស់ព្រឹទ្ធសភា សម្រាប់ឆ្នាំ២០១៣ ដោយគិតគូរបង្កើតឲ្យមានអង្គភាពថវិកា និងថវិកាតាមកម្មវិធីសំរាប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

ដោយឡែកនៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៣នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា យកចិត្តទុកដាក់ខ្ពស់លើការងារបណ្តុះបណ្តាលធនធានមនុស្ស ការអភិវឌ្ឍស្ថាប័ន ការផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត ក្នុងនោះទទួលបានជំនួយមួយចំនួនពីប្រកពចិន វៀតណាម ជប៉ុន និងម៉ាឡេស៊ី ។

ភាពជោគជ័យទាំងនេះ បង្ហាញឲ្យឃើញពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០១៣នេះ ។

ភ្នំពេញ,ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣

**អគ្គលេខាធិការ**

អ៊ុំ សារឹទ្ធ